អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១២

# សេចក្តីប្រកាសព័ត៌មាន

## ប្រទេសន័រវែសបានផ្តល់ជំនួយថវិកាបន្ថែមចំនួន ៦ លានក្រោន ដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

រដ្ឋាភិបាលន័រវែសបានផ្តល់ជំនួយថវិកាបន្ថែមទៀតចំនួន ៦ លាន ន័រវែសក្រោន (ប្រមាណ ១លាន ដុល្លារអាមេរិក) ដល់ភាគីអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។ បូករួមទាំងជំនួយលើកចុងក្រោយនេះផង ជំនួយថវិកាដែល អ.វ.ត.ក ទទួលបានពីប្រទេសន័រវែសមានចំនួនសរុបជាង ៥ លាន ដុល្លារអាមេរិកហើយ។

ឆ្លើយតបនឹងជំនួយសប្បុរសនេះ ឯកឧត្តម ក្រាញ់ តូនី ប្រធានការិយាល័យរដ្ឋបាលស្តីទី និងលោក វ៉ាជីវ គុមរ៉ា មន្ត្រីទទួលបន្ទុកការិយាល័យអនុប្រធានរដ្ឋបាលនៃ អ.វ.ត.ក បានថ្លែងថា៖ “យើងសូមថ្លែងអំណរគុណចំពោះរដ្ឋាភិបាលន័រវែស ដែលបានផ្តល់ជំនួយថវិកានៅក្នុងកាលៈទេសៈដែល អ.វ.ត.ក កំពុងតែប្រឈមមុខនឹងកង្វះខាតថវិកា។ ជំនួយនេះមានសារសំខាន់ក្នុងការធានាថា អ.វ.ត.ក អាចបន្តការងារដើម្បីបំពេញអាណត្តិរបស់ខ្លួនក្នុងការនាំយកយុត្តិធម៌ជូនប្រជាជនកម្ពុជាដោយពុំមានការផ្អាកជាបន្ទាន់ណាមួយ”។

ប្រទេសន័រវែសបានផ្តល់ការគាំទ្រនិងជំនួយដល់ អ.វ.ត.ក តាំងពីការចាប់ផ្តើមដំបូងនៅឆ្នាំ២០០៦។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទដៃ: +៨៥៥ (0)១២ ៤៨៨ ០២៣
សារអេឡិកត្រូនិក: olsenl@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យ អ.វ.ត.ក
ទូរស័ព្ទដៃ: +៨៥៥ (0)១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិក: neth.pheaktra@eccc.gov.kh